# ក្រូចច្របាច់

ពាក្យ៧

មនុស្សសើយសកសំបកចោល
កាយខ្ញុំត្រដោលសព្វទិសឋាន
នៅតែស្បែកក្នុងព័ទ្ធអង្គប្រាណ
ដែលគេមិនបានព្រលាត់ចេញ។

គេចោះគេឆ្កៀលវាលរូងរុក
បង្កើតជាមុខឲ្យបែកស្លេញ
ហើយគេច្របាច់បង្ហិលដេញ
ធ្វើម៉េចឲ្យចេញកើតជាទឹក។

ដៃអើយដៃប៉ិនកិនរូបកាយ
ឲ្យស្រៀវសុះសាយសប្បាយភ្លឹក
មាត់អើយប៉ិនបឺតបូមយកទឹក
ឲ្យក្រូចរលីកនឹកគ្រប់គ្រា។

មាត់ជញ្ជឹកលើដៃរើភាវក្រោម
លុញស្លៀមឆាយឆោមប្រាណរងារ
ឲ្យទ្រាំលែងបានលែងការពារ
បំពេញរកគ្នាជូនទឹកបងទៅ។

ចេញទឹកអស់ហើយខ្លួនអើយខ្សោះ
គេក្រវែងបោះលែងទុកពៅ
ចែកធុងសំរាមគ្រាន់រស់នៅ
ឲ្យរុយឃោឃៅចោមមាក់ងាយ។

២៣ ឧសភា ២០០៧

សូយ ឡូត